


# ដួងចិត្តខ្មែរ

លោកស្រី Marie Alexandre Martin[1], ស្ត្រីបារាំងសែសម្នាក់ ជាជម្នជាតិ និង ជាតិពិន្ទុវិទូ គាត់ធ្លាប់បានរស់នៅស្រុកខ្មែរ មួយរយះកាល បានសរសេរសៀវភៅ បោះផ្សាយនៅប្រទេសបារាំងនៅឆ្នាំ ១៩៨៩ ស្តីអំពី « អកុសលខ្មែរ »។ សៀភៅនេះ ជាផលានៃ ដំណើរសិក្សា នៅទស្សវត្សរ៍ ៦០ នៅស្រុកខ្មែរ និង សម្ភាសន៏នៅទស្សវត្សរ៍ ៧០ របស់លោកស្រី ជាមួយបញ្ញាវន្តខ្មែរមួយចំនួនរស់នៅស្រុកបារាំង។ នៅទីនេះ យើងលើកយក ផ្នែកមួយ នៅក្នុងសៀភៅ មានចំណងជើងថា « Khmerétude », ក្នុងនោះលោកស្រី ដកស្រង់យក គំនិត របស់បុគ្គលមួយក្រុម មានខ្មែរនិង បរទេស ដែលលោកស្រី បានធ្វើសម្ភាសន៏ ឬ បានអានអត្ថបទ ឬ សៀវភៅ នៃអ្នកទាំងនោះ មាន លោក សម សុខ (សម្ភាសន៏) និង ខ្មែរផ្សេងទៀត, វេជ្ជបណ្ឌិត Pannetier និង A. Pavie (សៀវភៅសរសេរនៅសម័យអណាព្យាបាលបារាំង)។

**នេះជា ចំណារចម របស់លោកស្រី :**

សង្គមខ្មែរ ជាសង្គមនៅនឹងថ្កល់ ក្នុងរចនាសម្ព័ន្ធបូរាណ ដែលនាំ៍ ចិត្តខ្មែរ គ្មានដូរសោះ តាំងពីបូរាណកាលមក : « ទន់ភ្លន់,

[1] Marie Alexandre MARTIN, naturaliste et ethnologue est directrice de recherche au CNRS. Le Mal cambodgien – Edition Hachette.

រួសរាយ, អៀនបៀន តែ លាក់ នូវការជំទាស់ និង សេចក្ដីក្រៀមក្រម នៅក្នុងចិត្ត ; មិនសូវចូលចិត្តពិភាក្សា និង ចូលចិត្ត នូវអ្វីដែលជា អំពើ បានធ្វើចប់សព្វគ្រប់ហើយ ; មាន មោទនភាពខ្លាំងក្លាណាស់ ទៅលើអតិតកាល តែមិនសូវរវល់នឹង យោបល់អ្នកដទៃ, គំនិត បើទ្វារ ដល់គំនិតទំនើប តែជា អ្នកអភិរក្ស ចំពោះអ្វីដែលនៅជុំវិញខ្លួន, ឆាប់ មានសេចក្ដីរីករាយខ្លាំង តែ មិនសូវមានអំណត់ ; ឆ្លាត, ចិត្តស្រាល តែចូលចិត្ត និយាយ កំប្លែង និង ការស៊ីផឹក »(នេះជាការយល់ឃើញ របស់លោក សម សុខ)។ គំនិតបំព្រួញដ៏ប្រពៃនេះ បង្ហាញច្បាស់ នូវសក្ដានុភាព នៃប្រជាជនខ្មែរ ដែលជាគុណសម្បត្តិអស្ចារ្យ របស់ខ្មែរ បើសិន ខ្លួន រើសចេញ នូវទម្ងន់ នៃប្រពៃណីបាន។

ខ្មែរ អាចរៀបរាប់ គ្មានសំរក់ទឹកភ្នែកមួយតំណក់ ដោយទឹកមុខញញឹម អំពី ភ័ព្វអាក្រក់ ពីអតិតកាល និង បច្ចុប្បន្នកាល នៃខ្លួន ប្រកបដោយ សេចក្ដីថ្លៃថ្នូរ។ នេះជាគំរូមួយ ដែលនាំអោយ ជនបរទេស ឆ្ងល់ ព្រោះ ដូចជាស្ដាប់ រឿងនិទាន ដ៏សាហាវយង់ឃ្នងមួយ រៀបរាប់ផ្ទាល់ ដោយជនរងគ្រោះពិត ដោយសំនៀងផ្អែមល្ហែម។ បើប្រសិន រឿងនេះ វារៀបរាប់ដោយ ប្រជាជនផ្សេងទៀត ច្បាស់ជាអ្នកស្ដាប់ ពិបាកនឹងទ្រាំស្ដាប់ណាស់។ នេះជា គោលការណ៍ របស់ខ្មែរ គឺ មិនរំខានអ្នកផង ដែលនាំអោយ គូសន្ទនា ពេញចិត្តនឹងស្ដាប់។ សេចក្ដីថ្លៃថ្នូរ ឋិតនៅលើផងដែរ នូវការបង្ហាញខ្លួន ចំពោះមុខអ្នកដទៃ ដោយស្លៀកពាក់ត្រឹមត្រូវ និង ងូតទឹកស្អាត (ខ្មែរងូតទឹក យ៉ាងតិចបំផុត

មួយដង ឬ ពីរដងក្នុងមួយថ្ងៃ) : ខ្មែរទាំងឡាយ ជាជនស្អាត និង ចូលចិត្តតែងខ្លួន ទៅតាមមធ្យោបាយ នៃខ្លួន។ ដូចគ្នានឹង ភូមិខ្មែរ មានការរៀបចំល្អប្រពៃ និង នៅកណ្ដាលទីក្រុង មានសភាពជាដ្ឋានរមទន ដែលទាក់ទាញ ភ្នែក និង អារម្មណ៍ អ្នកទេសចរ។ ពួកជនអ៊ឺរុប ដែលបានធ្វើការជាមួយខ្មែរ តែងតែពេញចិត្តនឹង ចរិយាល្អ របស់ដៃគូខ្លួន។ តែមាន អ្នកខ្លះ មិនយល់ថា ការស្លៀកពាក់កន្រ្តកកន្រ្តាក ឬ ចរិយា មិនសុភាព នៃខ្លួន ធ្វើអោយខ្មែរ ទាល់ចិត្តណាស់ ដូចគ្នានឹង ការនិយាយស្តី ជ្រុលហួស ដែលនាំអោយមាន ផលប៉ះពាល់អវិជ្ជមាន ចំពោះសេចក្តីគួរសមខ្មែរ។

ខ្មែរ ស្រឡាញ់ សេរីភាពបុគ្គល យ៉ាងស្វិតស្វាញ ហើយ សំដែង នូវកម្លាំងខ្លាំងក្លា ដើម្បីប្រឆាំងនឹងនរណា ដែលប៉ះពាល់ដល់សេរីភាពនោះ; ប៉ុន្តែខ្មែរ តែងតែសម្រុះសម្រួល ជានិច្ច ជាមួយអ្នកណា ដែលទុក លទ្ធភាព អោយខ្លួន ធ្វើសកម្មភាពដោយសេរី, អ្នកណា ចេះសំថៃដល់ ជម្រៅចិត្ត របស់ខ្លួន និង ជនបរទេសណា ដែលបង្ហាញ នូវសេចក្តីគួរសម និង អំណត់ ចំពោះខ្លួន ដូចខ្លួនមានចំពោះអ្នកនោះដែរ។ នៅចំពោះមុខ ជនបរទេស មិនស្គាល់, ខ្មែរ តែងតែ ប្រព្រឹត្តិតាមប្រពៃណី នៃខ្លួន, ហើយបើតម្រូវអោយខ្លួន ជួយទុក្ខធុរៈដល់ជននោះ គឺខ្លួនធ្វើដោយស្ម័គ្រចិត្ត។ តែទោះបីយ៉ាងណា ខ្មែរ តែងតែលាក់បាំងជិត នូវជីវិតខ្លួន ចំពោះ ជនបរទេស ហើយមិនចូលចិត្ត ជនណា ចូលជ្រៀតជ្រែកក្នុងជីវិតខ្លួន។ ដូចយ៉ាង សង់ សាលា ឬ ទីជម្រកដើម្បី

ទទួលភ្ញៀវ ដើម្បីមិនចង់អោយភ្ញៀវ ស្គាល់ក្នុងផ្ទះ របស់ខ្លួន (នេះជាការយល់ឃើញ របស់វេជ្ជបណ្ឌិត Pannetier)។ ពាក់ព័ន្ធនឹង ការងារ, លោក A. Pavie ធ្វើការកត់សម្គាល់ថា ខ្មែរ ទទួលស្គាល់តែ ឧត្តមភាព នៃជនអឺរ៉ុប តែមួយគត់ ដូច្នេះ ត្រូវជៀសវៀង ដាក់ខ្មែរនៅក្រោមបង្គាប់ នៃជនសៀម, ចិន ឬ យួន។ បើខ្មែរ គ្មានជម្រើស គឺប្រាកដ ជាខ្មែរ មិនសូវយកចិត្តទុកដាក់នឹង បញ្ហា នៃអ្នកត្រួតត្រានោះឡើយ ដែលនាំអោយ អ្នកទាំងនោះ យល់ច្រឡំថា ខ្មែរជាជន ខ្ជិលធ្វើការ។ ក្នុងការជជែកដេញថ្លៃ ជាមួយមេ ឬ ជនអឺរ៉ុប, ខ្មែរ បង្ហាញ នូវតម្លៃ របស់ខ្លួន ជាវិចារកៈ[2] ដ៏ប្រសប់។

ដូច្នេះ ខ្មែរ ស្រឡាញ់ពេញចិត្ត អោយគេ ចេះស្គាល់តម្លៃត្រឹមត្រូវរបស់ខ្លួន។ ការក្រអឺតក្រអោង គ្មានពិចារណា របស់អាមេរិកាំង នាំអោយទាល់ចិត្តខ្មែរណាស់។ រីឯ បារាំងសែស វិញ កាលពីសម័យអាណាព្យាបាល មិនសូវមាន ទទាស់ទទែងច្រើន ក្នុងការធ្វើសហការ ជាមួយខ្មែរ ព្រោះពួកគេ យល់ចិត្តគំនិតខ្មែរ។

ខ្មែរ, មានទ្រនង់[3], មិនព្រមទទួល នូវការឧបត្ថម ពីអ្នកដទៃដែលខ្លួនមិនបានស្នើសុំ។ ដូច្នេះ វាគ្មានប្រយោជន៍អ្វីនឹងទទូចនោះឡើយ ព្រោះ ខ្មែរ ទុកវា ជាការបំបាក់មុខខ្លួន។ ក៏ប៉ុន្តែ ខ្មែរដឹងគុណ អ្នក ដែលបានជួយខ្លួន ហើយទុកគុណនោះ ជាអនន្តគុណ។ តែ អ្នកជួយ បើបានជួយហើយ តែឆ្លៀតរិះគន់ គឺនាំ

[2] Négociateur.
[3] មោទនភាព លាយនឹង ក្រអឺតក្រអោង។

ឲខ្មែរ មានកំហឹងខ្លាំង ចំពោះអ្នកជួយនោះ ហើយ ដូរចិត្តខ្លួន តែមួយយប់ ចំពោះអ្នកនោះ ជួនរហូតដល់ទៅនិយាយអាក្រក់ ឬ បង្កាច់បង្ខូច ពីអ្នកនោះ ជាការផ្តន្ទាទោស ដោយគ្មានមូលដ្ឋានត្រឹមត្រូវ បើសិនជាអ្នកនោះ រិះគន់ដល់ស្រុកខ្មែរ។ ដូច្នេះ ត្រូវជៀសវៀង និយាយអ្វី នាំទាំចិត្តខ្មែរ។

ខ្មែរ មាន គុណសម្បត្តិ ដែលអោយខ្លួន មានលទ្ធភាព អាចវិវត្តន៏ ទៅតាមសម័យទំនើប, ដូចយ៉ាង ខ្មែរ មករស់នៅស្រុកបារាំង ជាឧទាហណ៏ចំណានមួយ បង្ហាញ នូវសមត្ថភាព នៃការសម្របខ្លួននេះ : មនុស្សពេញវ័យ នៅមានអកប្បកិរិយា ដូចរស់នៅស្រុកខ្មែរ, ក្មេងជំទង់ ទម្លាប់បាន តិច ឬ ច្រើន នូវការរស់នៅថ្មី របស់ខ្លួន។ រីឯ កុមារ កុមារី វិញ មានប្រតិកម្មតាមតែ ឫសកំណើត របស់ខ្លួន : បើជាកូនកសិករ ហើយនៅតែទទួលការអប់រំ តាមប្រពៃណីខ្មែរជ្រុលពេក, វានាំអោយកូនក្មេងទាំងនោះ មានការពិបាកនឹង ធ្វើតាមការសិក្សាបារាំង, កូនក្មេងផ្សេងទៀត រស់នៅក្នុងគ្រួសារ បោះបង់ របៀបរស់នៅខ្មែរបូរាណ, កូនក្មេងនោះ វាបង្ហាញ នូវគំនិត បើកទ្វារ ស្មើនឹងមិត្តភក្តិបារាំង របស់ខ្លួន។ វាគ្រាន់តែ មាតាបិតា ជួយបន្ថែមឲគ្នា ចេះភាសាខ្មែរ និង ប្រវត្តិសាស្ត្រជាតិខ្លួន វាអាចនឹងមានប្រយោជន៏ ដល់ប្រជាជាតិខ្មែរទៅអនាគត ព្រោះ យុវជន ជាអនាគត នៃប្រជាជាតិ។

សេចក្តីសន្និដ្ឋាន របស់យើង គឺ យើង អញ្ជើញខ្មែរម្នាក់ៗ អោយយកចំណារ របស់លោកស្រី Marie Alexandre Martin ខាងលើ

នេះ ទៅពិចារណាថា តើវាពិតជា ដួងចិត្តខ្មែរ មែនឬទេ ? តើខ្មែរសព្វថ្ងៃ មានដួងចិត្តបែបណា ?

នៅឆ្នាំ ១៩៧៣ លោក ប៉ុណ្ណចន្ទ ម៉ុល, អ្នកនយោបាយខ្មែរម្នាក់នៅទសវត្សរ៍ ៤០-៥០, បានសរសេរសៀវភៅ អំពី ដួងចិត្តខ្មែរ មានចំណងជើងថា « ចរិតខ្មែរ »។ សេចក្ដីនៅក្នុងសៀវភៅនោះគឺ បង្ហាញ នូវគុណវិបត្តិខ្មែរមួយចំនួន នៃ អ្នកនយោបាយខ្មែរជាទូទៅ ដែលជា កត្តាអវិជ្ជមាន សំរាប់ស្រុកខ្មែរ។ សួរថា តើគុណវិបត្តិនោះ វាជាពន្លឺឆ្លុះ នៃចរិតខ្មែរ ? តើ សេចក្ដីក្នុងសៀវភៅ របស់លោកស្រី Marie Alexandre Martin ដែលមានចំណងជើងថា « អកុសលខ្មែរ » អាចជាចម្លើយ ឬទេ ? យើងនឹងយកវាមកសិក្សានៅពេលក្រោយទៀត៕